N°15-16
30-4-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥លេខ ១៥_១៦ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I – ខុទ្ទកាល័យព្រះមហាក្សត្រ

១- ព្រះរាជក្រម

២៥.៤.៩៧	ព្រះរាជក្រម ជស/រកម/០៤៩៧/០២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ លើកទី ១ ១៩៩៦-២០០០	៩៥៣

២- ព្រះរាជក្រឹត្យ

១៨.៤.៩៧	ព្រះរាជក្រឹត្យ នស/រកត/០៤៩៧/២២ បន្ថយរយៈពេលជាប់ពន្ធនាគារអោយជលទណ្ឌិត	៩៥៥

II– រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៣.៤.៩៧	អនុក្រឹត្យលេខ ៤៣ អនក្រ.ពក ស្តីពីការកែសំរួល និងតម្លើងឋានន្តរ ស័ក្តិនាយទាហាន	៩៦៣

២- សេចក្តីសំរេច

២៣.៤.៩៧	សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការផ្ទេរសិទ្ធិ	៩៦៥
២៨.៤.៩៧	សេចក្តីសំរេចលេខ ១៦ សសរ បញ្ចប់ភារកិច្ច និង រំសាយគណៈកម្មាធិការសំរាប់សំរួលដោះស្រាយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយព្យ	៩៦៦

២៩.៤.៩៧ សេចក្ដីសំរេចលេខ ១៧ សសរ ស្ដីពីការកំណត់ផលិតផលឈើដែលត្រូវហាមឃាត់ និង ផលិតផលឈើដែលអនុញ្ញាតអោយធ្វើការនាំចេញ និង កំណត់ច្រកនាំចេញ ៩៦៨

II- ការងារបណ្ដាក្រសួង

១_ លិខិតការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១៨.៤.៩៧ ប្រកាសលេខ ១៣២ សហវ.ហក.ប្រក ស្ដីពីការចំណាយក្នុងជំពូក ៥០ ប្រការ ០២ ការរួមចំណែករបស់រាជរដ្ឋាភិបាល ចំពោះការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេសមូលនិធិបដិភាគ ៩៧៣

២៣.៤.៩៧ ប្រកាសលេខ ១៣៤ ប្រក.សហវ ស្ដីពីការប្រគល់ភារកិច្ចត្រួតពិនិត្យបេឡាសាច់ប្រាក់នៅតាមក្រសួង មន្ទីរ ស្ថាប័ន ៩៧៦

២_ លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៩.៤.៩៧ ប្រកាសលេខ ១៤១ ពណ.ពកប.ប្រក បង្កើតគណៈកម្មការត្រួតពិនិត្យបច្ចេកទេសរោងចក្រកាត់ដេរកម្ពុជា ៩៧៨

៣_ លិខិតការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២១.៤.៩៧ ប្រកាសលេខ ៣៨៩ ឧក.ប្រក អនុញ្ញាតអោយអ្នកស្រី តែ គីមហួយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំប៉័ង ៩៨១

២១.៤.៩៧ ប្រកាសលេខ ៣៩០ ឧក.ប្រក អនុញ្ញាតអោយលោក ឡៃ ហេង ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងជាងផលិតផាល ៩៨១

២១.៤.៩៧ ប្រកាសលេខ ៣៩១ ផក.ប្រក អនុញ្ញាតអោយលោក លីម ចាន់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម ៩៨២

២១.៤.៩៧ ប្រកាសលេខ ៣៩២ ផក.ប្រក អនុញ្ញាតអោយលោក ឈឿក សៅ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ៩៨២

២១.៤.៩៧ ប្រកាសលេខ ៣៩៣ ផក.ប្រក អនុញ្ញាតអោយលោក លីម ជា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ៩៨៣

២១.៤.៩៧ ប្រកាសលេខ ៣៩៤ ផក.ប្រក អនុញ្ញាតអោយលោក ឡាយ ថាវ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣០ សេះ ៩៨៣

២១.៤.៩៧ ប្រកាសលេខ ៣៩៥ ផក.ប្រក អនុញ្ញាតអោយលោក គុង ភិត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ៩៨៤

២១.៤.៩៧ ប្រកាសលេខ ៣៩៦ ផក.ប្រក អនុញ្ញាតអោយលោក ជា ធុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ៩៨៥

២១.៤.៩៧ ប្រកាសលេខ ៣៩៧ ផក.ប្រក អនុញ្ញាតអោយលោក យុ ស៊ុយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣១ សេះ ៩៨៥

២១.៤.៩៧	ប្រកាសលេខ ៣៩៨ ជក.ប្រក អនុញ្ញាតអោយលោក ហេង ហម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ	៩៨៦
២១.៤.៩៧	ប្រកាសលេខ ៣៩៩ ជក.ប្រក អនុញ្ញាតអោយលោក ជិន ទី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥១ សេះ	៩៨៦
២១.៤.៩៧	ប្រកាសលេខ ៤០០ ជក.ប្រក អនុញ្ញាតអោយលោក រឿន យន់ ជា ម្ចាស់រោងម៉ាស៊ីនកិនស្រូវកំលាំង ៩០ សេះ ផ្ទេរភារកិច្ចគ្រប់គ្រងជូន លោក ញែប សុភាព វិញ	៩៨៧
២១.៤.៩៧	ប្រកាសលេខ ៤០១ ជក.ប្រក អនុញ្ញាតអោយលោក ហួត វីក ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥៥ សេះ	៩៨៧
២១.៤.៩៧	ប្រកាសលេខ ៤០២ ជក.ប្រក អនុញ្ញាតអោយលោកឆម សុវណ្ណ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ	៩៨៨
២១.៤.៩៧	ប្រកាសលេខ ៤០៣ ជក.ប្រក អនុញ្ញាតអោយលោក អេង កុយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ	៩៨៩
២១.៤.៩៧	ប្រកាសលេខ ៤០៤ ជក.ប្រក អនុញ្ញាតអោយលោក ឡី ផាត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ	៩៨៩

២១.៤.៩៧	ប្រកាសលេខ ៤០៥ ផក.ប្រក អនុញ្ញាតអោយលោក គង់ ហេងងួន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ	៩៩០
២១.៤.៩៧	ប្រកាសលេខ ៤០៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ទុំ សំអាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ផ្ទេរភារកិច្ចគ្រប់គ្រងជូនលោក សួន វិសិទ្ធ វិញ	៩៩០
២១.៤.៩៧	ប្រកាសលេខ ៤០៧ ផក.ប្រក អនុញ្ញាតអោយលោក លី សុវត្ថា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងក្រឡឹងដែក និង ជួសជុលម៉ាស៊ីនគ្រប់ប្រភេទ	៩៩១
២៩.៤.៩៧	ប្រកាសលេខ ៤១៥ ផក.ប្រក អនុញ្ញាតិអោយលោក សុក ច្រាំង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតអេប៉ុង និង ជួសជុលកង់ឡាន	៩៩២
២៩.៤.៩៧	ប្រកាសលេខ ៤១៦ ផក.ប្រក អនុញ្ញាតិអោយលោក គៀត ចំរើន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងផ្សារដែក	៩៩២
២៩.៤.៩៧	ប្រកាសលេខ ៤១៧ ផក.ប្រក អនុញ្ញាតិអោយលោក ហេង ហួត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់ពីប្លាស្ទិច	៩៩៣
២៩.៤.៩៧	ប្រកាសលេខ ៤១៨ ផក.ប្រក អនុញ្ញាតអោយលោក ម៉ា គីមលី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់ពីប្លាស្ទិច	៩៩៣
២៩.៤.៩៧	ប្រកាសលេខ ៤២០ ផក.ប្រក អនុញ្ញាតអោយលោក លី ជិនលាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋក្បឿង	៩៩៤

២៩.៤.៩៧ ប្រកាសលេខ ៤២១ ផក.ប្រក អនុញ្ញាតអោយលោក គុជ ហេងរីដាវ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋក្បឿង ៩៩៤

២៩.៤.៩៧ ប្រកាសលេខ ៤២២ ផក.ប្រក អនុញ្ញាតអោយលោកគុង ជីងសេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា "វេន គង់ហួរ" ៩៩៥

២៩.៤.៩៧ ប្រកាសលេខ ៤២៣ ផក.ប្រក អនុញ្ញាតអោយលោក សាន ពាក្យ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៩៩៥

២៩.៤.៩៧ ប្រកាសលេខ ៤២៤ ផក.ប្រក អនុញ្ញាតអោយលោក គង់ កាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៩៩៦

២៩.៤.៩៧ ប្រកាសលេខ ៤២៥ ផក.ប្រក អនុញ្ញាតអោយលោក ឈឹម សុវណ្ណឈូរិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មកន្សែងក្រដាក់ ៩៩៧

២៩.៤.៩៧ ប្រកាសលេខ ៤២៦ ផក.ប្រក អនុញ្ញាតអោយលោក ហ៊ុយ ស៊ីម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតប្រេង សណ្តែក ៩៩៧

២៩.៤.៩៧ ប្រកាសលេខ ៤២៧ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ផេង ហេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង ៩៩៨

២៩.៤.៩៧ ប្រកាសលេខ ៤២៨ ផក.ប្រក អនុញ្ញាតអោយលោក អៀយ ស៊ីម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ ៩៩៨

៣០.៤.៩៧ ប្រកាសលេខ.៤២៩ ផក.ប្រក អនុញ្ញាតអោយលោក ប៊ុន ម៉េង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតស្ករស ៩៩៩

៣០.៤.៩៧	ប្រកាសលេខ ៤៣០ ផក.ប្រក អនុញ្ញាតអោយលោក ខូង ប៊ូ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតខ្សែចំណងនីឡុង	៩៩៩
៣០.៤.៩៧	ប្រកាសលេខ ៤៣១ ផក.ប្រក អនុញ្ញាតអោយលោក គុយ កេវ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចសំលាប់ស្បែក និង ផលិតបាតស្បែកជើង	១០០០
៣០.៤.៩៧	ប្រកាសលេខ ៤៣២ ផក.ប្រក អនុញ្ញាតអោយលោក ជី គង់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងគ្រឿងគ្រឿងបន្លាស់ម៉ូតូ	១០០០

៤— នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

២១.៤.៩៧	ប្រកាសលេខ ៣០២ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅផែនជីវិវិទ្យា "សំរាប់គ្រូថ្នាក់ទី ៨ "	១០០១
២១.៤.៩៧	ប្រកាសលេខ ៣០៣ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅរូបវិទ្យា "សំរាប់គ្រូថ្នាក់ទី ៨ "	១០០២
២១.៤.៩៧	ប្រកាសលេខ ៣០៤ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា "សំរាប់គ្រូថ្នាក់ទី ៨ "	១០០៤
២១.៤.៩៧	ប្រកាសលេខ ៣០៥ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសិក្សាសង្គម "សំរាប់គ្រូថ្នាក់ទី ២ "	១០០៥
២១.៤.៩៧	ប្រកាសលេខ ៣០៦ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ "សំរាប់សិស្សថ្នាក់ទី ៨ "	១០០៦
២៣.៤.៩៧	ប្រកាសលេខ ៣២១ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា "ក្រោលក្របាំង" មកជាសាលាបឋមសិក្សា "បុប្ផាវតី"	១០០៨

២៨.៤.៩៧	ប្រកាសលេខ ៣២៥ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "គោកចេះ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ	១០០៩
២៨.៤.៩៧	ប្រកាសលេខ ៣២៦ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ "សែនទាវ" មកជាសាលាបឋមសិក្សាពេញលក្ខណៈ	១០១១
២៩.៤.៩៧	ប្រកាសលេខ ៣២៨ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ បាទីទៅជាវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន "បាទី" ស្ថិតក្នុងឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ	១០១២
២៩.៤.៩៧	ប្រកាសលេខ ៣២៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន ក្នុងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម	១០១៤
២៩.៤.៩៧	ប្រកាសលេខ ៣៣០ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ រក្សជ័យ ទៅជាអនុវិទ្យាល័យ ជា ស៊ីម "រក្សជ័យ"	១០១៥
២៩.៤.៩៧	ប្រកាសលេខ ៣៣១ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ កំពង់ភ្នំ ទៅជាវិទ្យាល័យ ហ៊ុន សែន "កំពង់ភ្នំ" ស្ថិតក្នុងស្រុកលើកដែក ខេត្តកណ្តាល	១០១៦

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

ព្រះរាជក្រម ជស/រកម/០៤៩៧/០២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងផែនការ

ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំលើកទី១ ១៩៩៦_២០០០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំ លើកទី១ ១៩៩៦_២០០០

មាត្រា ១ : អនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមកិច្ច ៥ ឆ្នាំ លើកទី១ ១៩៩៦_២០០០ ដូចមានឯកសារភ្ជាប់មកជាមួយ ។

មាត្រា ២ : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច_សង្គមកិច្ច ៥ឆ្នាំ លើកទី១ ១៩៩៦_២០០០ នេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៧
ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
រដ្ឋមន្ត្រីក្រសួងផែនការ
ហត្ថលេខា
ជា ចាន់តូ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះរាជហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា
ហ៊ុន សែន

២_ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៤៩៧/២២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * * *

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០.៦.៨៨

* * *

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលជាប់ពន្ធនាគារពីអស់មួយជីវិតមកត្រឹម ២០ ឆ្នាំ អោយទណ្ឌិតចំនួន ០១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលទទួលរងទោសក្នុងពន្ធនាគារដូចមានរាយឈ្មោះខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ម៉ឿន សាម៉ើ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមអំណាច សាលក្រមលេខ ១៣ ចុះថ្ងៃទី ២៧.៦.៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ អោយទណ្ឌិតចំនួន១២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ខា ថនឌី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ២៣.៦.៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

២_ទណ្ឌិតឈ្មោះ **ឆាយ ថែន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ១៨.១០.៩១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **សាំង ណាំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៦_៦_៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **អាំ សុគុណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៦_៦_៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៥_ទណ្ឌិតឈ្មោះ **ឈុំ ជួន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៦_៩_៨៩ របស់តុលាការខេត្តព្រៃវែង ។

៦_ទណ្ឌិតឈ្មោះ **មូល ស៊ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាច សាលក្រមលេខ ៨ ចុះថ្ងៃទី ១១_១០_៨៦ របស់តុលាការខេត្តកំពត ។

៧_ទណ្ឌិតឈ្មោះ **តាន់ ឃូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាច សាលក្រមលេខ ៦ ចុះថ្ងៃទី ១៩_៩_៨៥ របស់តុលាការខេត្តកំពត ។

៨_ទណ្ឌិតឈ្មោះ **មាស ចាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ៣០_៨_៨៦ របស់តុលាការខេត្តកំពត ។

៩_ទណ្ឌិតឈ្មោះ **ញៀម ទិត ហៅ ស៊ិត ភារីម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ៣០_៨_៨៦ របស់តុលាការខេត្តកំពត ។

១០_ទណ្ឌិតឈ្មោះ **ឈុម ចាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨_២_៨៤ របស់តុលាការខេត្តកំពត ។

១១_ទណ្ឌិតឈ្មោះ **ស៊ុន ច្រេន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ១៩_៦_៨៥ របស់តុលាការខេត្តកំពត ។

១២_ទណ្ឌិតឈ្មោះ **ឯក សាគុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ២៥_៩_៩១ របស់តុលាការខេត្តស្វាយរៀង ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៩ខែ អោយទណ្ឌិតចំនួន ៧ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ឌឹម ឈាម ហៅ គោខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ២៤_១_៩១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

២_ទណ្ឌិតឈ្មោះ **និន ឈាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ២៣_៩_៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **ភាន់ ធំ ហៅ ភឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ១៩.១០.៩១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **ឡាង ធិតា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ១១_១១_៩១ របស់តុលាការខេត្តព្រៃវែង ។

៥_ទណ្ឌិតឈ្មោះ **ឡៅ ជីវ៉ុកមាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១០_៦_៩៣ របស់តុលាការខេត្តព្រៃវែង ។

៦_ទណ្ឌិតឈ្មោះ **សឿង សិាម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩ ចុះថ្ងៃទី ២៩_១០_៩១ របស់តុលាការខេត្តស្វាយរៀង ។

៧_ទណ្ឌិតឈ្មោះ **សៅ នន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៨_៨_៩០ របស់តុលាការខេត្តស្វាយរៀង ។

មាត្រា ៤ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ខែ អោយទណ្ឌិតចំនួន ២០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **សោម រួន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ២៣_១១_៩៣ របស់តុលាការខេត្តបន្ទាយមានជ័យ ។

២_ទណ្ឌិតឈ្មោះ **ឈិញ និត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ២៥_១១_៩៣ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៣_ទណ្ឌិតឈ្មោះ **សុ សយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ៣០_៧_៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៤_ទណ្ឌិតឈ្មោះ **អុល ឡូញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ២២_០១_៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៥_ទណ្ឌិតឈ្មោះ **សឿន សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ០២_០២_៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៦_ទណ្ឌិតឈ្មោះ **កុច គ្រីយ៉ា ហៅ តាន់ ម៉ុនថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ១៥_០២_៩៦ របស់តុលាការខេត្តបន្ទាយ មានជ័យ ។

៧_ទណ្ឌិតឈ្មោះ **ពៀយ ហ៊ាន** ដែលត្រូវបានផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ២៩_៨_៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៨_ទណ្ឌិតឈ្មោះ **ឆន អ៊ឺន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ១១_៦_៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៩_ទណ្ឌិតឈ្មោះ **ឆេញ សួរ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩៦ ចុះថ្ងៃទី ១៧_៦_៩៤ របស់តុលាការក្រុងភ្នំពេញ ។

១០_ទណ្ឌិតឈ្មោះ **ឡាំ ផល្លា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២១៦ ចុះថ្ងៃទី ២៨_៦_៩៤ របស់តុលាការក្រុងភ្នំពេញ ។

១១_ទណ្ឌិតឈ្មោះ **ថៃ យុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ០១_៤_៩៣ របស់តុលាការខេត្តព្រៃវែង ។

១២_ទណ្ឌិតឈ្មោះ **ខាន់ យឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ០១_៤_៩៣ របស់តុលាការខេត្តព្រៃវែង ។

១៣_ទណ្ឌិតឈ្មោះ **ចៅ នុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី ២៦_៤_៩៤ របស់តុលាការក្រុងព្រះសីហនុ ។

១៤_ទណ្ឌិតឈ្មោះ **ទេខ សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ ចុះថ្ងៃទី ១៨_៥_៩៤ របស់តុលាការក្រុងព្រះសីហនុ ។

១៥_ទណ្ឌិតឈ្មោះ **ទេព្យ ស៊ីណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ២៥_៨_៩៤ របស់តុលាការខេត្តកោះកុង ។

១៦_ទណ្ឌិតឈ្មោះ **ទណ្ណ ហឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៨_៣_៩៥ របស់តុលាការខេត្តកោះកុង ។

១៧_ទណ្ឌិតឈ្មោះ **ខ្មែរ ឆី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ១៨_៣_៩៥ របស់តុលាការខេត្តកោះកុង ។

១៨_ទណ្ឌិតឈ្មោះ **ឃួន មុំនណ្ណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ១៦_៩_៩៥ របស់តុលាការខេត្តកោះកុង ។

១៩_ទណ្ឌិតឈ្មោះ **ឈឹម ឆៃ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ ចុះថ្ងៃទី ២២_១២_៩៥ របស់តុលាការខេត្តកោះកុង ។

២០_ទណ្ឌិតឈ្មោះ **សោម សុគ័ន្ធ ហៅតៀ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៨_១១_៩៥ របស់តុលាការខេត្តស្ទឹងត្រែង ។

មាត្រា ៥ : ត្រូវលើកទោសអោយទណ្ឌិតចំនួន ១៧ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសកន្លងមក ដូចមានរាយនាមខាងក្រោម :

១_ទណ្ឌិតឈ្មោះ **ឃឹម សារី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១០_៨_៩៣ របស់តុលាការខេត្តស្ទឹងត្រែង ។

២_ទណ្ឌិតឈ្មោះ **ឆើន ការ៉ុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ២៦_១២_៩៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៣_ទណ្ឌិតឈ្មោះ **ម៉ៅ រ៉ាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ២០_១០_៩៥ របស់តុលាការខេត្តស្ទឹងត្រែង ។

៤_ទណ្ឌិតឈ្មោះ **ស៊ឹម ឃុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨៣ ចុះថ្ងៃទី ២៨_៩_៩៤ របស់តុលាការក្រុងភ្នំពេញ ។

៥_ទណ្ឌិតឈ្មោះ **អ៊ឿន ទ៉ុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨៣ ចុះថ្ងៃទី ២៨_៩_៩៤ របស់តុលាការក្រុងភ្នំពេញ ។

៦_ទណ្ឌិតឈ្មោះ **ឈឹម សាខន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ " ខ " ចុះថ្ងៃទី ២៩.៣.៩៥ របស់តុលាការក្រុងភ្នំពេញ ។

៧_ទណ្ឌិតឈ្មោះ **ស៊ុំ ស្រី** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ៣_៥_៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៨_ទណ្ឌិតឈ្មោះ **មុំ ឌុច** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ២៣_២_៩៤ របស់តុលាការក្រុងព្រះសីហនុ ។

៩_ទណ្ឌិតឈ្មោះ **អ៊ុក ស៊ិន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២២_៦_៩៥ របស់តុលាការក្រុងព្រះសីហនុ ។

១០_ទណ្ឌិតឈ្មោះ **ម៉េខ ឆាយ** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ខែ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ២៩_៨_៩៦ របស់តុលាការក្រុងព្រះសីហនុ ។

១១_ទណ្ឌិតឈ្មោះ **ចិក ចិន្ដា** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧" ត" ចុះថ្ងៃទី ៩_៨_៩៥ របស់តុលាការខេត្តកំពង់ចាម ។

១២_ទណ្ឌិតឈ្មោះ **ស៊ិន ចន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ៣_៧_៨៧ របស់តុលាការខេត្តកំពង់ចាម ។

១៣_ទណ្ឌិតឈ្មោះ **ខៀវ ចាន់** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ១៩_៨_៨៦ របស់តុលាការខេត្តតាកែវ ។

១៤_ទណ្ឌិតឈ្មោះ **ខ្លែម ណេាន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០៦_៩_៨៨ របស់តុលាការខេត្តតាកែវ ។

១៥_ទណ្ឌិតឈ្មោះ **កេន យ៉ុន** ហៅសារ៉េត ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៨_៧_៨៤ របស់តុលាការខេត្តតាកែវ ។

១៦_ទណ្ឌិតឈ្មោះ **ស៊ូ សុគាំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៩_១០_៨៧ របស់តុលាការខេត្តតាកែវ ។

១៧_ទណ្ឌិតឈ្មោះ **នង ទើត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ២៨_១១_៨៥ របស់តុលាការខេត្តកំពត ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៧ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - រាជរដ្ឋាភិបាល

១_ អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៤៣ អនក្រ.តត

ស្តីពីការកែសំរួល និង តម្លើងថ្នាក់ងារសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

ប្រការ ១ : ត្រូវបានកែសំរួល និង តម្លើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូននាយទាហានជាន់ខ្ពស់ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមនេះ ÷

១-លោកវរសេនីយ៍ទោ **សុខ យាន** មេបញ្ជាការរងកងឯកភាពអង្គរក្ស

២-លោកវរសេនីយ៍ទោ **សុខ សុវណ្ណ** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៣-លោកវរសេនីយ៍ទោ **សុខ ចារុណ្ណ** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៤-លោកវរសេនីយ៍ទោ **ឡេង សារុន** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៥-លោកវរសេនីយ៍ទោ **អ៊ុង សារិទ្ធ** មេបញ្ជាការរងឯកភាពអង្គរក្ស

៦-លោកវរសេនីយ៍ទោ **នួន ណារិន** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៧-លោកវរសេនីយ៍ទោ **សោម ជន** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៨_លោកវរសេនីយ៍ទោ **គង់ ចរណ្ណា** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៩_លោកវរសេនីយ៍ទោ **ស្រី សុផល** នាយសេនាធិការកងពលតូចលេខ ៧០

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង អស់លោកមានឈ្មោះខាងលើត្រូវអនុវត្តអនុក្រឹត្យនេះដែលចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

២_ សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៥ សសរ

ស្តីពីការផ្ទេរសិទ្ធិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ខាំ ចាន់តូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ រហូតដល់ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ខាំ ចាន់តូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទាយព្រះហស្តលេខា និង ហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៦ សសរ

******

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការចំរុះពិនិត្យស្រាវជ្រាវ និង ដោះស្រាយសភាពការណ៍មិនប្រក្រតីនៅខេត្តបាត់ដំបង

- បានឃើញសេចក្តីសំរេចលេខ ១២ សសរ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៧ ស្តីពីការបន្ថែមសមត្ថកិច្ចជូនគណៈកម្មការចំរុះ ដែលបានបង្កើតឡើងតាមសេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- បានឃើញ សេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់សំរួលដោះស្រាយ ឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយ័ព្យ
- ដើម្បីអោយគណៈកម្មការចំរុះ ដែលបានបង្កើតឡើងតាមសេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ បំពេញភារកិច្ចតាមសមត្ថកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូនប្រកបដោយប្រសិទ្ធភាពខ្ពស់

សំរេច

ប្រការ ១ : បញ្ចប់ភារកិច្ចនិង រំសាយគណៈកម្មាធិការសំរាប់សំរួលដោះស្រាយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងសង្គមជាតិទិសពាយ័ព្យ ដែលបានបង្កើតឡើងតាមសេចក្តីសំរេចលេខ ៣៤ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : រាល់ការងារដែលសេសសល់ គណៈកម្មាធិការសំរាប់សំរួលដោះស្រាយជួយឧបត្ថម្ភដល់បងប្អូនមករួមរស់ក្នុងជាតិទិសពាយ័ព្យ ត្រូវផ្ទេរអោយគណៈកម្មការចំរុះដែលបានបង្កើតតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ០៨ សសរ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ អនុវត្តបន្ត ។

ប្រការ ៣ : គណៈកម្មការចំរុះនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន និង លេខាធិការដ្ឋានដើម្បីជួយធ្វើការងារខ្លួន ។

ប្រការ ៤ : គណៈកម្មការចំរុះ ត្រូវធ្វើគំរោងថវិកាដែលចាំបាច់ត្រូវចំណាយសំរាប់ការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចដោយគិតក្នុងជំពូកចំណាយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៥ : សេចក្តីសំរេចរបស់គណៈកម្មការចំរុះ ត្រូវកំណត់តាមមតិភាគច្រើននៃសមាជិកដែលបានចូលរួមប្រជុំ ហើយត្រូវបានចុះហត្ថលេខាដោយឯកឧត្តម**ស ខេង** ឧប

នាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឯកឧត្តម **ទា បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ គណៈកម្មការចំរុះ និង ស្ថាប័នពាក់ព័ន្ធ ទទួលភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៧ សសរ

ស្តីពីការកំណត់ផលិតផលឈើដែលត្រូវហាមឃាត់ និង ផលិតផលឈើដែលអនុញ្ញាតអោយធ្វើការនាំចេញនិងការកំណត់ច្រកនាំចេញ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ ច្បាប់លេខ ៣៥ ក្រច. ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០២ សប្រក ចុះថ្ងៃទី ២៦-១២-១៩៩៦ ស្តីពីការហាមឃាត់ការនាំចេញឈើហ៊ុប និងឈើអារពីព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

សំរេច

ប្រការ ១ : បង្កើនទូវប្រសិទ្ធភាពនៃការគ្រប់គ្រងនិងលុបបំបាត់ភាពអាណាធិបតេយ្យក្នុងវិស័យព្រៃឈើ ។

ប្រការ ២ : **ហាមឃាត់ការនាំចេញនូវ** ÷

១-ឈើហ៊ុប ទោះបីបកសំបក ឬ ទាំងសំបក

២-ឈើអារសុទ្ធសាធ

៣-ឈើជ្រុងដែលមានកំរាស់លើសពី ២៥ ស.ម ទោះបីបានឈូសហើយក៏ដោយ

៤-អុស គ្រប់ប្រភេទ ទោះបីចងជាបាច់ក៏ដោយ

៥-ធ្យូងឈើ

-រូបភាពមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសេចក្តីសំរេចនេះ ។

ប្រការ ៣ : អនុញ្ញាតអោយធ្វើការនាំចេញនូវ ផលិតផលឈើកែច្នៃ ដូចខាងក្រោម ÷

១-គ្រឿងសង្ហារឹម គ្រឿងផ្គុំសំរាប់សង្ហារឹម និង គ្រឿងផ្គុំទូឯកសារ

២-ឈើគ្រឿងចម្លាក់ ឧបករណ៍ក្មេងលេង

៣-ឈើប៉ាកេ និង ឈើកាំរ៉ូក្រាល

៤–ឈើប៉ារ៉ឡែត និង ឈើធ្វើឡាំង(ផ្លិរួច ឬ មិនទាន់ផ្គុំ)

៥–ឈើលាក់ ឬ លកញ្ចីឈ្មោល ឈើក្រឡឹង និង ខាត់ គ្រោងទ្វារ បង្អួច ឈើមានដំណាប់ ឬពន្លូញញីឈ្មោល (ឈើធ្វើជងឧបករណ៍ប្រើ ប្រាស់)

៦–ផលិតផលឈើបិទភាវជាបន្ទះ ឬ ជាចំណិតភ្ជាប់គ្នា

៧–ក្តារធ្វើពីកំទេចឈើ ក្រោមសម្ពាធខ្លាំង និងក្តារបន្ទះ(កុងប្លាកេ)

៨–ឈើរនៀរ ឈើចិត ឈើចៀរជាសន្លឹក

៩–ឈើអារតាមខ្នាតទទឹងសាច់ឈើដែលមានកំរាល់អតិបរមា ១៥ ស.ម ទោះបីនៅជាប់សំបក ក៏ដោយ

១០–ឈើឈូសមុខ២ ឬ មុខ៤(S2S) (S4S) ព្រមទាំងមានខ្នាត និង គុណភាពនាំចេញ

១១–ចំណាំងកំទេចឈើ–ម្សៅឈើ

១២–ឈើគូស ឈើចាក់ធ្មេញ ចង្កឹះ

១៣–ឈើកំណល់ផ្លូវរថភ្លើង(លើកលែងឈើប្រណិត)

១៤–ឈើជ្រុងដែលមានទោល ឬ បន្ទារអតិបរមា ២៥ស.ម ដែលបានសំងួត តាមលក្ខណៈធម្ម ជាតិ ឬ ក្នុងឡសំងួតតាមលក្ខណៈបច្ចេកទេស ។

ចំពោះប្រភេទផលិតផលឈើកែច្នៃខាងលើនេះ ត្រូវយកចិត្តទុកដាក់សំខាន់ដល់ការនាំចេញ ប្រភេទផលិតផលឈើកែច្នៃដែលមានតំលៃបន្ថែមខ្ពស់ (High value added)

ប្រការ ៤ : លក្ខខ័ណ្ឌនៃការនាំចេញ :

ផលិតផលឈើកែច្នៃអនុញ្ញាតអោយធ្វើការនាំចេញបាន លុះត្រាតែមានប្រភពពីឈើហ៊ុបមូលដែលបានមកពីការធ្វើអាជីវកម្ម ក្នុងព្រៃសម្បទានដែលរាជរដ្ឋាភិបាលអនុញ្ញាតតាមលក្ខណៈបច្ចេកទេស ត្រឹមត្រូវតាមច្បាប់ និងមានការត្រួតពិនិត្យពីនាយកដ្ឋានរុក្ខា–ប្រមាញ់ ព្រមទាំងបំពេញបែបបទនាំចេញត្រឹមត្រូវ ។ ថ្លៃឈើឈរ និង ពន្ធគ្រប់ប្រភេទស្របតាមច្បាប់ហិរញ្ញវត្ថុ និង

ច្បាប់វិនិយោគ ត្រូវបង់អោយបានចប់សព្វគ្រប់មុនពេលធ្វើការនាំចេញ ។ បែបបទនាំចេញត្រូវសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនសិន ទៅតាមករណីនិមួយៗ ទើបអនុញ្ញាតអោយចេញអាជ្ញាប័ណ្ណជាក្រោយ ។

ប្រការ ៥ : ច្រកអនុញ្ញាតនាំចេញ :

ផលិតផលឈើកែច្នៃអនុញ្ញាតអោយធ្វើការនាំចេញតាមបណ្តាច្រកអន្តរជាតិដូចខាងក្រោម÷

១- កំពង់ផែពាណិជ្ជកម្មអន្តរជាតិ ក្រុងព្រះសីហនុ

២- កំពង់ផែពាណិជ្ជកម្មអន្តរជាតិ រាជធានីភ្នំពេញ ឆ្លងកាត់ច្រកក្អមសំណ

៣- ច្រកផ្សេងទៀតអាចអនុញ្ញាតអោយនាំចេញបានដោយមានការសំរេចពីរាជរដ្ឋាភិបាលកម្ពុជា

ប្រការ ៦ : រាល់សេចក្តីសំរេច និង ប្រកាសដែលផ្ទុយ និង សេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួងពាក់ព័ន្ធមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

ឧបសម្ព័ន្ធ (ភ្ជាប់នឹងសេចក្តីសំរេចលេខៈ ១៧សសរ ចុះថ្ងៃទី២៩ ខែមេសាឆ្នាំ១៩៩៧)

ការកំណត់ផលិតផលឈើ ដែលត្រូវហាមឃាត់
និង ផលិតផលឈើដែលអនុញ្ញាតអោយធ្វើការនាំចេញ

*****

កំនូរបង្ហាញអំពីផលិតផលឈើ សំរាប់ស្វែងយល់
ការអនុវត្តន៍សេចក្តីប្រកាស
<u>ផលិតផលឈើហាមឃាត់នាំចេញ</u>



ឈើហ៊ុបមូល



ឈើអារសុទ្ធសាធ



ឈើបួនជ្រុងស្មើ ដែលមានជ្រុងធំជាង 25 ស.ម



ឈើថាមពល

ធ្យូង

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣២ សហវ.ហក.ប្រក

ស្តីពីការចំណាយក្នុង ជំពូក ៥០ ប្រការ ០២

ការរួមចំណែករបស់រាជរដ្ឋាភិបាលចំពោះ

ការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេសមូលនិធិបដិភាគ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** លេខ ០១ នស ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** លេខ ១០៩៤ ៨៣ នស ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិ នៃ គណៈរដ្ឋមន្ត្រី

- បានឃើញច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម នស.រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ គ្រប់គ្រងច្បាប់ ហិរញ្ញវត្ថុ និងប្រព័ន្ធថវិកា
- បានឃើញព្រះរាជក្រមលេខ ១២៩៥ នស ០៧ ចុះថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ បញ្ញត្តទៅលើ គណនេយ្យសាធារណៈ
- កិច្ចព្រមព្រៀងឥណទានរវាងរាជរដ្ឋាភិបាលកម្ពុជានិងអ្នកផ្តល់ជំនួយ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : រាល់ការចំណាយដែលទាក់ទងនឹងការរួមចំណែករបស់រាជរដ្ឋាភិបាល ទៅនឹងគំរោងដែលវិនិយោគផ្ទាល់ពីបរទេសហៅកាត់ថា «មូលនិធិបដិភាគ» ស្ថិតក្នុងជំពូក ៥០ ប្រការ ២ នៃ ថវិកាត្រូវអនុវត្ត និង ត្រួតពិនិត្យផ្នែកតាមប្រការទាំងឡាយដូចខាងក្រោម :

ប្រការ ២ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាអាណាប័កតែមួយគត់លើការចំណាយក្នុងជំពូក ៥០.២ នេះ។

ប្រការ ៣ : រាល់សំណើសុំចំណាយ ភ្នាក់ងារអនុវត្តគំរោងត្រូវផ្ញើមក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ជាបឋមមានភារៈត្រួតពិនិត្យផ្ទៀងផ្ទាត់លើសំណើទាំងនេះ ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងក្របខ័ណ្ឌកាតព្វកិច្ច

រួមចំណែករបស់រាជរដ្ឋាភិបាល និង គោលការណ៍ណែនាំ និង នីតិវិធីលទ្ធកម្ម ស្របតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយមុននឹងបញ្ជូន ទៅនាយកដ្ឋានវិនិយោគ និង អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីអនុវត្តនីតិវិធី ចំណាយជាធរមាន ។

ប្រការ ៤ : នីតិវិធីចំណាយ អនុវត្តចំពោះជំពូកនេះ ត្រូវសមស្របតាមមាត្រាទី ១០ និងទី ១២ ដល់ទី ១៤ នៃ អនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ យោងខាងលើ ។

ប្រការ ៥ : អនុញ្ញាតិអោយភ្នាក់ងារអនុវត្តគំរោងបើកគណនីពិសេសមូលនិធិបដិភាគក្នុង រូបភាពជារដ្ឋទេយ្យបុរេប្រទាន សំរាប់បំរើអោយការទូទាត់ដែលមានទឹកប្រាក់មិន លើសពី ៧០ លានរៀល ។ ទឹកប្រាក់អតិបរមានៃគណនីពិសេសគឺ អាស្រ័យ នឹងសេចក្តីសំរេចរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដោយផ្អែកតាមភាព ជាក់ស្តែង នៃគំរោង ។ រាល់ការបំពេញឡើងវិញនូវគណនីពិសេស គឺអាស្រ័យ លើសំណើរបស់ភ្នាក់ងារអនុវត្តគំរោងដោយផ្អែកលើរបាយការណ៍ចំណាយ និង លិខិតបញ្ជីយុត្តិការដែលបានប្រតិបត្តិការរួចមកហើយ ។

រាល់ការទូទាត់ដែលមានទឹកប្រាក់លើសពី ៧០ លានរៀល ត្រូវអនុវត្តតាមនីតិ វិធីចំណាយជា ធរមាន។

ប្រការ ៦ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានពាក់ព័ន្ធ ត្រូវទទួល បន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៤ ប្រក.សហវ

ស្តីពីការប្រគល់ភារកិច្ចត្រួតពិនិត្យបេឡា

សាច់ប្រាក់នៅតាមក្រសួង មន្ទីរ ស្ថាប័ន

*****

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤-១០-៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤-៤-៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨-១២-៩៣ ។
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជ ក្រមលេខ នស.រកម ១.២៩៥-០៧ ចុះថ្ងៃទី ៣១-១២-៩៥
- បានឃើញអនុក្រឹត្យលេខ ៨២អ.ន.ក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៨ ប្រកសហវ ចុះថ្ងៃទី ២៣-១១-៩៤ ស្តីពីការជំរះបញ្ជី ការទូទាត់ប្រាក់ចំណូល និង ចំណាយ

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ២០ មករា ឆ្នាំ ១៩៩៧ស្តីពីការកំរិតកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋដែលគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ ឬ អង្គភាពនីមួយអាចរក្សាទុក នៅក្នុង បេឡារបស់ខ្លួន
- បានឃើញការចាំបាច់នៃការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចបន្ថែមអោយធនាគារជាតិ ក្នុងការចុះធ្វើការត្រួតពិនិត្យបេឡាសាច់ប្រាក់ នៅតាមបេឡារបស់គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ និង របស់ក្រសួង មន្ទីរ ស្ថាប័នដែលមានចំណូល ។

ប្រការ ២ : មន្ត្រីរបស់ធនាគារអាចចុះទៅធ្វើការត្រួតពិនិត្យបេឡាសាច់ប្រាក់ នៅតាមបេឡារបស់គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ និង របស់ក្រសួង មន្ទីរ ស្ថាប័នបានលុះត្រាតែ :

ក-នៅថ្នាក់កណ្តាល

មានលិខិតបញ្ជាបេសកកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើ របស់លោកប្រធានធនាគារជាតិ។

ខ-នៅខេត្ត ក្រុង

មានលិខិតបញ្ជាបេសកកម្មដែលចេញដោយអភិបាលខេត្ត ក្រុង តាមសំណើ របស់ប្រធានធនាគារខេត្ត ក្រុង ។

ប្រការ ៣ : ក្រោយពីចុះធ្វើការត្រួតពិនិត្យ :

ក-នៅថ្នាក់កណ្តាល

ប្រធានធនាគារជាតិត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ-នៅខេត្ត-ក្រុង

ប្រធានធនាគារខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនអភិបាលខេត្ត-ក្រុង និង ជូន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈធនាគារជាតិ ។

ប្រការ ៤ : លោកអគ្គនាយក នាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធានរតនាគារ ជាតិ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា

គាត ឈន់

* * *

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៤១ ពណពកបប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

****

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ។

-បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបច្ចេកទេសរោងចក្រកាត់ដេរលេខ ១០០ សជណ.ពហ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

-ពិនិត្យលើការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យបច្ចេកទេស រោងចក្រកាត់ដេរកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១-លោក ង៉ាន់ អៃ តំណាងក្រសួងពាណិជ្ជកម្ម	ជាប្រធាន
២-លោក ហូ វិចិត្រ តំណាងក្រសួងឧស្សាហកម្ម	អនុប្រធាន
៣-លោក អ៊ុយ សារិន តំណាងទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៤-លោក ជា ហាក់ តំណាងទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៥-លោក ជា វុទ្ធី តំណាងគណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក
៦-លោក ដួង ធារ៉ូ តំណាងគណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក
៧-លោក ឈៀង វិបុល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨-លោក ហាន់ ពន្ធគុណ តំណាងក្រសួងសង្គមកិច្ច	សមាជិក
៩-លោក ហ៊ុង លឹម ហ៊ាន តំណាងក្រសួងសង្គមកិច្ច	សមាជិក
១០-លោក និក ដារ៉ារិទ្ធិ តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
១១-លោក វ៉ាន់ ណារិទ្ធ តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
១២-លោក ឃៀក ជួន តំណាងកាំកុងត្រូល	សមាជិក
១៣-លោក P.steele ទីប្រឹក្សាសហគមអឺរ៉ុបអមក្រសួងពាណិជ្ជកម្ម	សមាជិក
១៤-លោក យា ប៊ុនណា តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល	សមាជិក
១៥-លោក Van Sou Ieng តំណាងសមាគមកាត់ដេរកម្ពុជា	សមាជិក
១៦-លោក L ee Thai Khit តំណាងសមាគមកាត់ដេរកម្ពុជា	សមាជិក
១៧ -លោក Roger Tan តំណាងសមាគមកាត់ដេរកម្ពុជា	សមាជិក

១៨–លោក សុខ ហុង តំណាងសមាគមកាត់ដេរកម្ពុជា សមាជិក

១៩–ទីប្រឹក្សា ១ ឬ ២រូប ដែលជ្រើសរើសដោយសមាគមកាត់ដេរកម្ពុជា សមាជិក

ប្រការ ២ : គណៈកម្មការមានភារកិច្ច :

–ត្រួតពិនិត្យ តាមដានការអនុវត្តរបស់អ្នកវិនិយោគទុន តាមបទដ្ឋានបច្ចេកទេស និងតាមគោលការណ៍និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលចំពោះអ្នកវិនិយោគទុនដែលទទួលផលប្រយោជន៍ពី MFN/GSP ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

–សហការជាមួយភ្នាក់ងារសមត្ថកិច្ចទាំងឡាយ ដើម្បីទប់ស្កាត់ការក្លែងបន្លំដែលធ្វើអោយខូចឈ្មោះនិង ប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ។

–សិក្សាស្រាវជ្រាវ និងកែសំរួលអោយកាន់តែសក្រិតចំពោះគោលការណ៍ដែលមានរួចហើយ ។

–គណៈកម្មការអាចបង្កើតក្រុមការងារ ជាជំនួយក្នុងករណីចាំបាច់ ។

ប្រការ ៣ : គណៈកម្មការត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង បណ្ដាក្រសួងពាក់ព័ន្ធលើផ្នែកជំនាញ ក្នុងករណីចាំបាច់ត្រូវសុំសេចក្ដីសំរេចពីគណៈរដ្ឋមន្ត្រី ។

ប្រការ ៤ : គណៈកម្មការត្រួតពិនិត្យបច្ចេកទេសរោងចក្រកាត់ដេរកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រាក្រសួងពាណិជ្ជកម្មក្នុងរយៈកាលដំណើរការ ។

ប្រការ ៥ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៦ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និង អស់លោកដែល មានឈ្មោះខាងលើត្រូវអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៣៨៩ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី តែ **គឹមហ្វយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ត្រលេខ០៧៨៨៨៨៨ ប.ប ចុះថ្ងៃទី១៥-១០-៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិរំពេក ១ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការសិប្បកម្ម ផលិតនំប៉័ង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣៩០ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងជាងផលិតដាល់ ដែលមានលោក **ឡៃ ហ៊ាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៣២៣៩ ប.ប ចុះថ្ងៃទី១៥-៨-៩០ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ១៨ ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ក្រុមទី ១៨ ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣៩១ ឥក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនផលិតទឹកកកដើម ដែលមានលោក **លឹម ចាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១៦១៧៣ ប.ប ចុះថ្ងៃទី ០៤–០២–៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយចៅ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយចៅ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៩២ ឥក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈៀក សៅ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៣៣០០ ប.ប ចុះថ្ងៃទី ១១–០២–៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកនរិន្ទ១ ឃុំ ព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឈៀក សៅ** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស

ច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៩៣ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លឹម ខា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥០៧០៧ ប.ប ចុះថ្ងៃទី ២៧–៣–៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់សំបួរ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **លឹម ខា** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៩៤ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាយ ខាង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៤៥១៧ ប.ប ចុះថ្ងៃទី ០១–៣–៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកន្សែបន្ទាយ ឃុំ មោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ នៅក្នុងទីតាំងភូមិកកោះ ឃុំកកោះ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឡាយ ថាច** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៣៩៥ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ទូច គិត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៤៧០៣ ប.ប ចុះថ្ងៃទី ០៤-០៣-៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិរលួស ឃុំ មោង ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិស្ទឹងថ្មី ឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ទូច គិត** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣៩៦ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវ ដែលមានលោក **ខា នួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៧៣០៣ ប.ប ចុះថ្ងៃទី ០២–៣–៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិរាមគន់ ឃុំ តាគ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិរាមគន់ ឃុំតាគ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ខា នួន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

